## ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
## សេចក្តីប្រកាសព័ត៌មាន

# ប្រឡងប្រជែងថ្លែងសុន្ទរកថាភាសាជប៉ុនលើកទី២០

ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៧

ស្ថានទូតជប៉ុនមានសេចក្តីសោមនស្សរីករាយជម្រាបជូនថា ស្ថានទូតរួមសហការជាមួយមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន(CJCC) និង វិទ្យាស្ថានភាសាបរទេសនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ(IFL) នឹងរៀបចំនូវកម្មវិធី **ប្រឡងប្រជែងថ្លែងសុន្ទរកថាភាសាជប៉ុនលើកទី២០នៅកម្ពុជា** នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៧ នៅ CJCC។ CJCC បានចាប់ផ្តើមទទួលពាក្យសុំការចូលរួមប្រឡងប្រជែងពីសំណាក់អ្នកសិក្សាភាសាជប៉ុន។

ការប្រឡងប្រជែងថ្លែងសុន្ទរកថាភាសាជប៉ុនត្រូវបានប្រារព្ធជារៀងរាល់ឆ្នាំ ក្នុងគោលបំណងផ្សព្វផ្សាយការអប់រំភាសាជប៉ុននៅកម្ពុជា និង រៀបចំឱកាសសម្រាប់អ្នកសិក្សាភាសាជប៉ុនបង្ហាញនូវជំនាញនៃការនិយាយ។

ពាក្យសុំចូលរួមប្រឡងប្រជែង ទទួលត្រឹមថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៧ នៅ CJCC រាល់ម៉ោងធ្វើការ ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹក ម៉ោង ៧:៣០-១១:៣០ និង ពេលរសៀល ម៉ោង១៣:៣០-១៧:០០។

ពាក្យសុំ និង សេចក្តីណែនាំពីការចូលរួមប្រកួត អាចរកបាននៅលើទំព័រហ្វេសប៊ុក CJCC ដែលមានអាស័យដ្ឋានខាងក្រោម៖
(https://www.facebook.com/cjcc.fb/photos/a.193791777354300.48553.120614181338727/1320925351307598/?type=3)។

ស្ថានទូតទន្ទឹងរង់ចាំអ្នកសិក្សាភាសាជប៉ុនជាច្រើនរូបទទួលយកឱកាសនេះ ដើម្បីបង្ហាញនូវសមត្ថភាពរបស់ខ្លួន ក្នុងការនិយាយភាសាជប៉ុន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងទៅកាន់ CJCC តាមរយៈទូរស័ព្ទលេខ ០២៣ ៨៨៣ ៨៩៩ ឬក៏ផ្ញើអ៊ីម៉ែលមកកាន់អាស័យដ្ឋាន៖ jcd@cjcc.edu.kh។

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023 217 161*
*Email: info.jpn@pp.mofa.go.jp*
*Official Website: www.kh.emb-japan.go.jp*